# ការតភ្ជាប់អាជ្ញាធរ និងសង្គមស៊ីវិល



កុមារគ្រប់រូបកើតមកមានសិទ្ធិទទួលបាននូវការអប់រំ ហើយសិទ្ធិមួយនេះមានសម្រាប់កុមារគ្រប់រូបដោយគ្មានការរើសអើង មិនចំពោះពូជសាសន៍ ឬវណ្ណៈសង្គមរបស់ពួកគេឡើយ។ ផ្ទុយទៅវិញ នៅក្នុងសហគមន៍ជនជាតិដើមភាគតិចខេត្តរតនគិរីវិញ កុមារភាគច្រើន ជួបនូវភាពលំបាកខ្លាំងក្នុងការទទួលបានការអប់រំថ្នាក់មូលដ្ឋាន ពីព្រោះពួកគេត្រូវដើរឆ្ងាយពីផ្ទះរបស់ពួកគេទៅកាន់ភូមិមួយទៀត ដើម្បីទទួលបាននូវការអប់រំទាំងនេះ។ សម្រាប់ករណីភូមិចាំងវាលវិញ (សហគមន៍ជនជាតិដើមភាគតិចគ្រឹង) កុមារដែលរស់នៅក្នុងភូមិនេះ ត្រូវដើរចំងាយ ៤៤គីឡូម៉ែត្រ ពីភូមិរបស់ពួកគេទៅកាន់ទីប្រជុំជនស្រុកអូរជ្រៅ ដើម្បីរៀននៅសាលារដ្ឋក្នុងស្រុកមួយនេះ។

ដើម្បីបំពេញសិទ្ធិក្នុងការទទួលបានការអប់រំសម្រាប់កុមារ គម្រោងអាយស៊ីស៊ី-អាយប៊ីស៊ីឌីអី ប្រចាំខេត្តរតនគិរី (អប់រំ និងអភិវឌ្ឍន៍ សហគមន៍ផ្អែកលើអត្តសញ្ញាណ) បាននឹងកំពុងធ្វើការកៀរគរអ្នកភូមិចាំងវាលរួមគ្នា ចូលរួមវេទិកាមួយដែលពួកគេអាចធ្វើការពិភាក្សា និងឆ្លុះបញ្ចាំងលើបញ្ហាដែលកើតឡើងនៅក្នុងសហគមន៍របស់ពួកគេ និងកំណត់អាទិភាព។ ជាលទ្ធផល សហគមន៍មួយនេះ បានកំណត់អាទិភាពរបស់ពួកគេទៅលើការអប់រំ និងការសង់សាលារៀន។ ដើម្បីសំរេចបានគោលដៅមួយនេះ អ្នកភូមិចាំងវាលត្រូវការការសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន និងសង្គមស៊ីវិល។

នៅពេលដែលកិច្ចប្រជុំប្រចាំឆ្នាំរបស់ភូមិចាំងវាលប្រារព្ធឡើង ដោយមានការចូលរួម ពីតំណាងការិយាល័យស្រុក ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ អង្គការសហគមន៍ និងក្រុមការងាររបស់គម្រោងអាយប៊ីស៊ីឌីអី អ្នកភូមិបានធ្វើការលើកឡើង ពីបំណងដ៏ធំបំផុតរបស់ពួកគាត់ក្នុងការកសាងសាលារៀន ពីព្រោះពួកគាត់យល់ច្បាស់ពីសារៈសំខាន់នៃការអប់រំសម្រាប់អនាគតរបស់កុមារ នៅភូមិរបស់ពួកគាត់។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំប្រចាំឆ្នាំនេះ អ្នកតំណាងប្រចាំភូមិចាំងវាល ក៏បានចែករំលែកអំពីផែនការសកម្មភាពរបស់ពួកគេ និងលើកឡើងពីតម្រូវការរបស់ពួកគេក្នុងការប្រើប្រាស់ដីសហគមន៍សម្រាប់ការសាងសង់សាលារៀន ក៏ដូចជាធ្វើការសំណូមពរឲ្យមានគ្រូបង្រៀនក្របខណ្ឌរបស់រដ្ឋមកបង្រៀននៅតាមភូមិរបស់ពួកគេ។ ជាលទ្ធផល អ្នកតំណាងការិយាល័យស្រុក និងឃុំបានសន្យាថា ពួកគេនឹងចាត់គ្រូបង្រៀនកិច្ចសន្យាមកបង្រៀនលក្ខណៈការអប់រំក្នុងប្រពន្ធនៅក្នុងភូមិចាំងវាល។ សាលារៀន ត្រូវបានសាងសង់ឡើងដោយប្រើប្រាស់ធនធានដែលមានស្រាប់នៅក្នុងសហគមន៍ ដូចជាឈើ និងសម្ភារសំណង់ផ្សេងៗទៀត។ ការសាងសងសាលារៀន នេះត្រូវបានបញ្ចប់នៅខែមេសា ឆ្នាំ២០១៨ និងចាប់ផ្តើមបើកទទួលសិស្សឲ្យចូលរៀនចាប់ពីពេលនោះមក។

បច្ចុប្បន្ននេះ ក្រៅពីការអប់រំក្នុងប្រពន្ធនៅភូមិចាំងវាល គម្រោងអាយប៊ីស៊ីឌីអី កំពុងផ្តល់ជូននូវថ្នាក់អក្ខរកម្មភាសាកំណើត ដល់សិស្សានុសិស្សតាមរយៈគ្រូបង្រៀនស្ម័គ្រចិត្ត។ គម្រោងអាយប៊ីស៊ីឌីអី បានបណ្តុះបណ្តាលអ្វីដែលចាំបាច់បំផុត ទៅដល់គ្រូបង្រៀនស្ម័គ្រចិត្ត ដើម្បីកសាងសមត្ថភាពរបស់ពួកគាត់ផ្ទាល់ក្នុងការបង្រៀន។ គ្រូបង្រៀនស្ម័គ្រចិត្តទាំងអស់ ក៏អាចបន្តការសិក្សារបស់ខ្លួនផ្ទាល់បានចាប់ពីថ្នាក់ទី០៩ នៅសាលារដ្ឋ ប្រសិនបើពួកគាត់បានបង្រៀនកុមារយ៉ាងតិច ០៣ឆ្នាំ ក្នុងថ្នាក់អក្ខរកម្មភាសាកំណើតរបស់អាយស៊ីស៊ី ស្របតាមលក្ខខណ្ឌដែលបានតម្រូវពីមន្ទីរអប់រំខេត្ត។ អាយស៊ីស៊ី ចង់ឃើញ គ្រូស្ម័គ្រចិត្តទាំងអស់អាចបន្តការសិក្សារបស់ខ្លួន ដល់ថ្នាក់ឧត្តមសិក្សា បន្ទាប់ពីបានធ្វើការជាមួយអាយស៊ីស៊ី។ ជាមួយគ្នានេះដែរ អាយស៊ីស៊ីសង្ឃឹមថានៅពេលអនាគត គ្រូបង្រៀនដែលគម្រោងអាយប៊ីស៊ីឌីអី ប្រចាំខេត្តរតនគិរី បានបណ្តុះបណ្តាលនោះ នឹងត្រឡប់មកវិញ ក្នុងឋានៈជាគ្រូបង្រៀនពេញសិទ្ធ ដើម្បីផ្តល់នូវការអប់រំដែលតម្រូវ ទៅដល់កុមារដែលពួកគេមានសិទ្ធិទទួល នៅក្នុងសហគមន៍ជនបទ។

នេះគឺជាឧទាហរណ៍ដ៏ល្អមួយ អំពីការតភ្ជាប់រវាងអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងប្រជាជនក្នុងសហគមន៍ក្នុងការចូលរួមគ្នា ដើម្បីសម្រេចបាននូវគោលដៅរួមមួយ គឺការផ្តល់ការអប់រំទៅដល់ក្មេងៗជំនាន់ក្រោយ។ ចំណុចសំខាន់មួយនៃយុទ្ធសាស្រ្តផ្តោតរបស់អាយស៊ីស៊ី គឺសង្គមស៊ីវិលសកម្ម ហើយអាយស៊ីស៊ី មានសេចក្តីរីករាយយ៉ាងខ្លាំង នៅពេលដែលឃើញ ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងភូមិចាំងវាល មានសកម្មភាពសកម្ម ហើយបុគ្គលម្នាក់ៗមានមោទនភាព និងភាពជាម្ចាស់ការទៅលើសកម្មភាពរបស់ខ្លួនក្នុងការអភិវឌ្ឍសហគមន៍។ សកម្មភាព និងកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ គឺដើម្បីការអភិវឌ្ឍសហគមន៍ ហើយការអភិវឌ្ឍនេះ គឺផ្តល់នូវអត្ថប្រយោជន៍ដល់កុមារឲ្យក្លាយខ្លួន ទៅជាអក្ខរជនដែលក្នុងពេលអនាគត នឹងចូលរួមចំណែកឆ្ពោះទៅកាន់ការកាត់បន្ថយភាពក្រីក្រ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព នៅក្នុងភូមិរបស់ពួកគេផ្ទាល់។

កាលបរិច្ឆេទ៖ វិច្ឆិកា ២០១៨